សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ពាក្យខ្មែរថាជ្រកក្រោមម្លប់ពោធិ៍
## និងពាក្យថាព្រះបាទធម្មិក តើមានន័យយ៉ាងណា ?

www.hoksavann.org

ថ្ងៃទី២១ មីនា ២០១២



ពាក្យខ្មែរទាំងពីរនេះ  កើតពីចាស់បូរាណខ្មែរពោលឡើងតាមការពិសោធន៍  និងតាមការចំណាំរបស់គាត់ ។ ពាក្យថា «ជ្រកក្រោមម្លប់ពោធិ៍» បើពោលជាអត្ថានុរូប គឺពោលចំតាមពាក្យបានសេចក្តីថា អ្នកធ្វើដំណើរក្រោមកំដៅថ្ងៃខ្លាំង លុះឃើញដើមពោធិ៍ក៏ប្រញាប់ប្រញាល់ទៅជ្រកក្រោមម្លប់ដើមដើមពោធិ៍ ដើម្បីឲ្យបានត្រជាក់ស្រួលខ្លួន មុននឹងធ្វើដំណើរទៅមុខទៀត ។ បើពោលជាអត្ថប្បដិរូប គឺន័យប្រៀបធៀបវិញ ជ្រកក្រោមម្លប់ពោធិ៍   គឺម្លប់ព្រះពុទ្ធសាសនាហ្នឹងឯង ។ ទំនងជាចាស់បូរាណខ្មែរ បំណាងពោលម្លប់ព្រះពុទ្ធសាសនានេះតែម្តង ។ ពាក្យថា «ពោធិ៍» បើនិយាយពីដើមរុក្ខជាតិ គឺដើមពោធិ៍ព្រឹក្ស  ដែលព្រះសម្ពុទ្ធបានត្រាស់ដឹងនៅក្រោមដើមពោធិ៍ព្រឹក្សនេះឯង ។  តាមស័ព្ទបាលី «ពោធិ»  បើនិយាយជាសម្មាធិដ្ឋានប្រែថា ការត្រាស់ដឹងនូវអរិយសច្ច៤ បើនិយាយជាបុគ្គលាធិដ្ឋាន ពោធិ ឬពោធី បានដល់ព្រះពុទ្ធហ្នឹងតែម្តង ។ សេចក្តីថា ប្រជាពលរដ្ឋខ្មែរបានរស់នៅជាមួយព្រះពុទ្ធសាសនា  បានទទួលនូវសេចក្តីសុខក្សេមក្សាន្ត  បើមានទុក្ខតែងរត់រកព្រះធម៌នៃព្រះពុទ្ធសាសនា ដើម្បីជួយបំបាត់ទុក្ខ ។ ក្នុងន័យនេះដែរ ចំពោះអ្នកដឹកនាំរដ្ឋ បើដឹកនាំធ្វើឲ្យប្រជាពលរដ្ឋរងទុក្ខវេទនា ក្រីក្រលំបាក បាក់បែកសាមគ្គីគ្នា រំលោភសិទ្ធិគ្រប់បែបយ៉ាងរបស់ប្រជាពលរដ្ឋ រហូតដល់ធ្វើឲ្យប្រទេសបាត់បង់ទឹកដីជាដើម  អ្នកដឹកនាំបែបនេះពុំមែនជាម្លប់របស់ប្រជាពលរដ្ឋឡើយ  ប្រជាពលរដ្ឋពិតជាស្វែងរកម្លប់ថ្មីវិញពុំខាន ។ ម្លប់ព្រះពុទ្ធសាសនាជាម្លប់ដ៏ត្រជាក់ ព្រោះបុគ្គលណាប្រតិបត្តិតាមទានសីលភាវនា ឬសីលសមាធិបញ្ញា ជននោះអាចរំលត់នូវភ្លើងទុក្ខ ភ្លើងកិលេស ធ្វើឲ្យចិត្តបរិសុទ្ធស្ងប់ ដែលជាឫសគល់នៃសុខសន្តិភាព ។

ពាក្យថា «ព្រះបាទធម្មិក» ពុំមែនសំដៅយកព្រះពុទ្ធត្រាស់ដឹងទេ ទំនងជាចាស់បូរាណខ្មែរ សំដៅយកអ្នកដឹកនាំដែលមានធម៌ក្នុងខ្លួន  ។  បើព្រះរាជាសំដៅយកព្រះរាជាប្រកបដោយទសពិធរាជធម៌១០យ៉ាង  ព្រោះកាលពីសម័យដើម  អ្នកកាន់អំណាចរដ្ឋស្ថិតនៅលើព្រះរាជាស្ទើរគ្រប់ប្រទេស  ។  អ្នកកាន់អំណាចស្ថិតនៅក្នុងធម៌  គឺអ្នកកាន់អំណាចបំរើផលប្រយោជន៍ប្រជាពលរដ្ឋ គោរពសិទ្ធិប្រជាពលរដ្ឋ មិនលំអៀងដោយអគតិធម៌ជាដើម ។ អ្នកខ្លះយល់ថា ព្រះបាទធម្មិកសំដៅយកព្រះពុទ្ធពុំទាន់ត្រាស់ដឹង គឺព្រះសិអារ្យមេត្រី ។ គេប្រាថ្នាឲ្យជួបព្រះសិអារ្យមេត្រី ដើម្បីឲ្យបានសំរេចធម៌ជាន់ខ្ពស់ គឺមគ្គផលនិព្វាន ។ ពាក្យថា «ធម្មិក» ជាពាក្យខ្មែរ ដែលចេញមកពីភាសាបាលីថា ធម្មិកោ ប្រែថា ប្រកបដោយធម៌ បើមនុស្សគឺមនុស្សមានធម៌ បើវត្ថុសំដៅយកវត្ថុដែលបានមកដោយធម៌ គឺពុំបានមកដោយការលួចជាដើម ដូចបាលីវេរចង្ហាន់ថា ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ  គឺរបស់ដែលយកមកធ្វើទាននេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ។ ពោលដូច្នេះ ដើម្បីកុំឲ្យព្រះសង្ឃដែលទទួលយកទៅ ប្រើប្រាស់យកទៅឆាន់មានការសង្ស័យ ។ ពាក្យថា «ធម្មិក» នេះ សំដៅយកបុគ្គលទូទៅដែលប្រព្រឹត្តល្អ ដោយកាយវាចាចិត្ត មិនបៀតបៀនអ្នកដទៃ រកស៊ីធ្វើការត្រឹមត្រូវ ដោយហោចមានសីលប្រាំ ។ ពាក្យថា «ព្រះបាទ» ជាពាក្យខ្មែរសម័យដើម ដែលហៅសំដៅទៅលើអ្នករដ្ឋការថ្នាក់កណ្តាល ថ្នាក់ខ្ពស់ ដូចហៅអភិបាលខេត្តថា «ព្រះបាទម្ចាស់» ។ ដូច្នេះពាក្យថា «ព្រះបាទធម្មិក» សំដៅយកអ្នកដឹកនាំជាន់ខ្ពស់ អ្នកកាច់ចង្កូតរដ្ឋ ដែលមានគុណធម៌ក្នុងខ្លួនមានការគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋ គោរពតាមច្បាប់របស់ប្រទេសជាដើម ។ បើមានបញ្ហាកើតឡើងថ្នាក់ជាតិបានដោះស្រាយដោយសន្តិវិធីតាមច្បាប់របស់ប្រទេសមិនប្រើអំពើហិង្សា។ តាមការពិតគេពុំអាចជ្រើសរើសអ្នកដឹកនាំឲ្យបានល្អឥតខ្ចោះនោះទេ ប៉ុន្តែគេអាចជ្រើសរើសអ្នកល្អគ្រាន់បើជាងគេ គឺអ្នកល្អគ្រាន់បើដោយការប្រៀបធៀបគ្នា ។ ដូចជាប្រៀបធៀបថា  អ្នកនេះមានវិជ្ជាចេះដឹងច្រើន និងមានចរិយាល្អជាងអ្នកនោះជាដើម ។ តាមរបបប្រជាធិបតេយ្យសេរី អំណាចរដ្ឋកើតមកពីប្រជាពលរដ្ឋ គឺប្រជាពលរដ្ឋជាម្ចាស់អំណាច  ដូច្នេះបើភ្នាក់ងារជាន់ខ្ពស់កាន់ការរដ្ឋប្រព្រឹត្តខុស  ប្រជាពលរដ្ឋមានសិទ្ធិដកហូតចេញពីតំណែង ។ ដោយអ្នកកាន់អំណាចរដ្ឋប្រព្រឹត្តអំពើផ្តាច់ការ   មិនបំរើផលប្រយោជន៍របស់ខ្លួន   ទើបប្រជាពលរដ្ឋក្រោកឡើងស្វែងរកព្រះបាទធម្មិក គឺអ្នកដឹកនាំប្រកបដោយធម៌ បំរើផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ ។ តាមរបបប្រជាធិបតេយ្យ ការជ្រើសរើសអ្នកដឹកនាំជាន់ខ្ពស់ឲ្យកាន់ការរដ្ឋ ដូចជារដ្ឋ សភា រដ្ឋាភិបាល គឺគេធ្វើតាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌  ក្នុងចំណោមគណបក្សដែលបានឈរឈ្មោះ  ។  បើតាមអត្ថន័យរបស់ព្រះពុទ្ធសាសនា  ដើម្បីឲ្យទៅជាព្រះបាទធម្មិកត្រូវជ្រកក្រោមម្លប់ពោធិ៍ គឺម្លប់ព្រះពុទ្ធសាសនា ដោយប្រតិបត្តិតាមធម៌ព្រះពុទ្ធ   ដូចជាមានទសពិធរាជធម៌ជាដើម  ទើបត្រូវតាមបំណាងរបស់ប្រជាពលរដ្ឋ ដែលត្រូវជ្រើសរើសឲ្យធ្វើជាអ្នកដឹកនាំ ។៚

*   *

*